លេខ ២

ROYAUME DU CAMBODGE
DEPOT LEGAL

P.K. 7
1956-2

ទស្សនាវដ្ដីចេញរាល់ខែ

ខែតុលា ឆ្នាំ១៩៥៦

R. 62-10-56

ឆ្នាំទី១ លេខ២ ខែតុលា ១៩៥៦

2.10.56

ទស្សនាវដ្តី

# នៃសមាគមសាមគ្គីសិស្សចាស់និងមិត្តសិស្សចាស់

# នៃអនុវិទ្យាល័យ និង វិទ្យាល័យស៊ីសុវត្ថិ

ទីសំណាក់ការ លេខ ១៣០ វិថី ប៉ាស្ទ័រ ភ្នំពេញ

[illegible]

ភាគទី ២

[illegible]

[illegible]

[illegible]

# មាតិការឿង


| | ទំព័រ |
|---|---|
| សកម្មភាពសមាគម | ១ |
| ទំព័រអក្សរសាស្ត្រ (វិជ្ជា) | ៣ |
| បញ្ហាអនាម័យ | ១១ |
| សេន្ធិកិច្ច (ត្រែត traite) | ១៧ |
| កីឡា (អត្តពលកម្ម) | ២០ |
| សកម្មភាពនិស្សិតសកលលោក | ២៥ |
| កំណាព្យខ្មែរ | ២៩ |
| សៀវភៅដែលគួរអាន | ៣៣ |
| លទ្ធផលនៃការសិក្សា | ៣៥ |
| នាមនិស្សិតខ្មែរដែលត្រូវទៅបន្តវិជ្ជានៅបរទេស | ៣៧ |
| សំនួរកំសាន្ត | ៣៩ |


## ថ្លៃជាវ

ក្នុងប្រទេស

| ១ ក្បាល | ៦ ខែ | ១ ឆ្នាំ |
|---|---|---|
| ១០រ | ៥០រ | ១០០រ |

ក្រៅប្រទេស

| ១ក្បាល | ៦ ខែ | ១ឆ្នាំ |
|---|---|---|
| ១៣រ | ៦០រ | ១២០រ |

*សូមផ្ញើអាណត្តិទៅលោក ស៊ុត - ត្នុល* លេខ១៣០ វិថីប៉ាស្ទ័រ ភ្នំពេញ

# សកម្មភាពសមាគម

ដោយមានបំណងនឹងរិះរកមធ្យោបាយ សម្រាប់អប់រំវប្បធម៌ទៅចំពោះសមាជិកសមាគមនឹងចំពោះមហាជន គណកម្មាធិការសមាគមបានតាក់តាំងបណ្ណាល័យនៅទីសំណាក់ការលេខ ១៣០ វិថីប៉ាស្ទ័រ ។

សូមអញ្ជើញសមាជិក នឹងអស់លោកអ្នកដែលមិនមែនសមាជិកក៏ដោយ ចូលមកអានសារពត៌មាន-ទស្សនាវដ្តីផ្សេងៗដែលសមាគមបានរៀបចំទុកចែកជូនមើលតាមសេចក្តីត្រូវការ ។

---

ម្យ៉ាងទៀតមានបើកបន្ទប់រៀននៅទីសំណាក់ការដដែល សម្រាប់និស្សិតនឹងសិស្សមករៀនខ្លួនឯង ក្នុងបរិយាកាសមួយស្ងប់ស្ងាត់នៅពេលក្រៅម៉ោងរៀននៅសាលា ។

ដើម្បីនឹងផ្គត់ផ្គង់នូវសម្ភារៈសិក្សាសម្រាប់បណ្ណាល័យ សមាគមបានស្នើសុំអំណោយពីសារពត៌មានខ្មែរទាំងអស់រៀងរាល់លេខ ។

យើងសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ

លោកបានហ្វាន់សោរពត៌មានៈ

អេណីតេកាំប៊ូងសៀន - ប្រជុំរបស់ - ប្រជាជន - ជាតិខ្មែរ - ឈាមខ្មែរ - មនុស្ស - អង្គរ ដែលបានផ្ញើព័ត៌មាន តាមសេចក្តីស្នើសុំរបស់យើង ។

កន្ទុំតែកញ្ញា សមាគមមានសេចក្តីសោមនស្ស ទទួលការសុំចូលជាសមាជិកចំនួនប្រាំពីរនាក់ ។

សមាគមមានសង្ឃឹមថានឹងមានសមាជិកថ្មីទៀត សុំចុះឈ្មោះចូលជាលំដាប់ ដូចជាសិស្សវិទ្យាល័យស៊ីសុវត្ថិ ដែលទើបនឹងឈប់រៀន ហើយបានចូលធ្វើរាជការថ្មី ៗ និងនិស្សិតដែលទើបត្រឡប់មកពីបរទេស ។

---

ឃ្លា ង　　　អស់កម្លាំងហៅល្ងើយល្ងង

ញ្ញា ញ៉ា　　　ណាស់ ពេលហ្នឹង ឥតឧបមា

ស្រឡាញ់　　　ពេញចិត្តស្និទ្ធស្នេហា

ល្អ　　　ឥតណាមកផ្ទឹមបាន ។

(ញ៉ុង-សឿន)

ស្រង់ពីទស្សនាវដ្តីកម្ពុជសុរិយា

# ទំព័រអក្សរសាស្ត្រ

**វិជ្ជា** (តនិងចប់)

សុវិជ្ជា – នៅទស្សនាវដ្ដីមុនយើងបានឃើញថា អ្វីដែលយើងហៅថា ទុវិជ្ជា ។ នៅពេលនេះយើងសូមអធិប្បាយពីសុវិជ្ជាម្ដង ។

នៅក្នុងសង្គមដែលគេប្រកាន់កសាងមនុស្ស កសាងជាតិឡើងពីទាបទៅខ្ពស់វិញ ឧត្តមគតិគេ គឺនិយមយកវិជ្ជាជាមធ្យោបាយល្ដោះមនុស្ស ល្ដោះជាតិជាកផុតទុក្ខល្ងង់ខ្លៅ ។ កាលបើគេមានគំនិតប្រសើរយ៉ាងនេះហើយ គេគិតធ្វើម្ដេចរកមធ្យោបាយផ្សាយវិជ្ជាឲ្យបានទូទៅដល់ប្រជាជនភាគច្រើន ព្រោះគេគិតឃើញថា នៅក្នុងស្រុកនីមួយ ៗ បើមានមនុស្សចេះចំនួនតិចស្ដួចស្ដើងពេក ហើយទុកឲ្យមនុស្សទាំងលាននាក់ល្ងង់ខ្លៅ វាខូចប្រយោជន៍ដល់ស្រុកទាំងមូល ដល់ជាតិទាំងមូល ដោយហេតុមនុស្សចេះភាគតិច ដែលគ្មានមហាជនឯទៀតក្នុងស្រុកជួយឧបត្ថម្ភយោបល់ផង អាចវង្វេងដោយងាយ ចូលក្នុងសិងពួកបុទ្ទិកដី ។ ពួកនេះបំរុងតែខ្លួនចូលជ្រៀតជ្រែកនៅក្រោម

ទិសទី នឹងគ្រប់ឱកាសដែលវាធ្លាក់ចុះ ។ អាស្រ័យលើហេតុសំខាន់នេះ
គេខំបណ្តុះគំនិតឲ្យមនុស្សយល់ហើយឃើញយ៉ាងជាក់ស្តែងថា «ចេះមកពី
រៀន» មិនមែនចំណេះនូវមកពីទេវតាដៅទុកមកពីមុន ឬក៏កម្មផលហុចជូន
មកឲ្យទេ ។ ភស្តុតាងនៅនឹងភ្នែកយើងពល់គ្នាស្រាប់ គឺស្រុកខ្មែរយើងនេះ
ឯង កាលក្នុងសម័យប្រទេសយើងនៅជាអាណានិគមគេ តើខ្មែរយើងមាន
អ្នកនិពន្ធកាសែតប៉ុន្មាន ? មានអ្នកនិពន្ធសៀវភៅប៉ុន្មាន ? មានអ្នក
ភ្លេងប៉ុន្មាន ? ------ ។ល។ ចុះឥឡូវដែលស្រុកយើងបានឯករាជ
ដែលយើងគ្រប់គ្រងខ្លួនយើង ដែលយើងមានសិទ្ធិសេរីភាព តើកាសែត
មានប៉ុន្មានវិញ ? សៀវភៅមានប៉ុន្មានវិញ ? យើងមានអ្នកភ្លេងនឹងគេឬទេ ?
ពិតមែនតែចំណេះទាំងនេះយើងមានស្តួចស្តើងនៅឡើយ ហើយនៅឆ្ងាយពីការ
បរិសុទ្ធច្រើននៅឡើយ ។ ទោះយ៉ាងណាក៏ដោយ យើងឃើញថាកាលណា
យើងខំរៀន យើងក៏បានចេះដូចគេ ហើយនេះគ្រាន់តែទើបនឹងចាប់ផ្តើមដំបូង
ផងទេ ។ បើប្រសិនជាខ្មែរយើងកាន់តែចេះស្រុះស្រួលរួបរួមគ្នាឲ្យបានកាន់តែ
ជិតស្និទ្ធឡើងទៀតក្នុងការស្វែងវិជ្ជានោះ មុខជាយើងបានចំរើនលើសនេះទៅ
ទៀត ជាពិតប្រាកដគ្មានសង្ស័យទេ ។ ឧទាហរណ៍មានច្រើនទៅទៀត
ដូចជាស្រុកដែលទើបនឹងរួចពីក្រញាំចក្រពត្រ គេឃើញថាសាលាមានហួ

ហៀរហូតដល់ស្រែចំការ ។ នេះបង្ហាញឲ្យឃើញថា ក្នុងស្រុកនិមួយៗ បើអ្នកដឹកនាំស្រុកមានគំនិតស្មោះត្រង់ ចង់ផ្សាយវិជ្ជាឲ្យដល់ប្រជាជនទូទៅពិតមែន គ្មានឧបសគ្គអ្វីមកពាំងគេបានឡើយ ក្នុងការអនុវត្តន៍ឲ្យបានសម្រេចនូវឧត្តមគតិរបស់គេនោះ ព្រោះប្រជាជនគេដែលបានទទួលផលប្រយោជន៍ដ៏វិសេសនេះ មានតែអបអរសាទរ ជួយឧបត្ថម្ភកាន់តែខ្លាំងឡើង ៗ យ៉ាងនេះហើយបានជាគេត្រូវតែរំលាយរបងជាន់ថ្នាក់ ដែលឃាំងមិនឲ្យមនុស្សបានចេះដឹងច្រើនគ្នាឲ្យអស់ពេញ ។ គេត្រូវតែជំរុញមនុស្សឲ្យខំរៀនសូត្ររៀងៗខ្លួនឡើង កុំឲ្យបណ្តោយខ្លួនឲ្យសេចក្តីល្ងង់ខ្លៅញាំញីខ្លួនបាន ។ មិនតែប៉ុណ្ណោះ គេថែមទាំងខំរកមធ្យោបាយជួយឧបត្ថម្ភ ជួយធ្វើឲ្យការស្វែងវិជ្ជាទៅជាការមួយងាយចំពោះជនភាគច្រើនទៀតផង ។ គេយល់ថាមនុស្សចេះច្រើនគ្នានាំឲ្យការធ្វើស្រួល នាំឲ្យនគរគេបានចំរើន នាំគ្រប់មុខផ្នែកការបានលឿនរហ័ស ព្រោះថាគេគ្មានចង់ គ្មានប្រាថ្នាជិះជាន់គ្នាទេ ។ គេប្រាថ្នាតែជួយគ្នាទៅវិញទៅមកដោយស្មោះស្ម័គ្រដើម្បីរស់នៅឲ្យបានសុខទាំងអស់គ្នា ។ គេប្រកាន់គំនិតនឹងអាកប្បកិរិយាដូច្នេះ មិនចំពោះតែជនជាតិរបស់គេទេ ជាមួយស្រុកឯណាក៏ដោយ ធំក្តី តូចក្តី ក៏គេប្រើគំនិតប្រើអាកប្បកិរិយានេះដែរ ។

ហេតុអ្វីក៏ដូច្នេះ? ថាមកពីគេយល់ឃើញថា ក្នុងសាកលលោកទាំង

មូល បើស្រុកទាំងឡាយ ជនជាតិទាំងឡាយ បេះដូងស្មើគ្នាឡើង វាជាការងាយប្រាស្រ័យទាក់ទងគ្នា ជាការងាយសម្រុះសម្រួលគ្នា រួមរស់នៅក្នុងសន្តិភាព ។

អាស្រ័យគំនិតទូលាយមើលឃើញវែងឆ្ងាយដូច្នេះ គេខំបណ្តុះសាលារៀនដូចផ្សិត ដើម្បីឲ្យគ្រប់គ្រាន់នឹងចំនួនជនជាតិគេដែលត្រូវការសិស្សវិជ្ជា ។ គេនិយមភាសាជាតិជាធំក្នុងការសិក្សាដើម្បីឲ្យជនជាតិគេភាគច្រើន បានស្រូបយកចំណេះវិជ្ជាដោយងាយ ហើយបានចេះពិតប្រាកដមែនទែនផង ។ ក្នុងការកសាងជាដំបូង គេរើសយកមុខវិញ្ញាសារណាដែលមានប្រយោជន៍ជាងគេដល់ជាតិ ដើម្បីតែងជាកម្មវិធីសំរាប់ការសិក្សា ។ ដូចជានៅស្រុកខ្មែរយើងក្នុងបច្ចុប្បន្នសម័យ ខាងគំនិតយើងត្រូវបណ្តុះគំនិតឲ្យជនជាតិយើងចេះតាំងខ្លួនជាជនជាតិឯករាជ ។ ឯខាងមុខវិជ្ជាវិញ យើងត្រូវការនឹងចំណេះខាងបច្ចេកទេសច្រើនជាងគេដើម្បីកសាងសេដ្ឋកិច្ចជាតិយើង ។ ដែលនិយាយយ៉ាងនេះយើងសូមបញ្ជាក់ថា យើងមិនមែនឲ្យបោះបង់ចោលចំណេះឯទៀតក្រៅពីបច្ចេកទេសនោះទេ គឺយើងគ្រាន់តែសុំឲ្យគិតពីវិជ្ជាបច្ចេកទេសច្រើនជាងគេ ព្រោះថាយើងកំពុងត្រូវការណាស់សព្វថ្ងៃ ។ ដើម្បីអនុវត្តនូវគំនិតថាត្រូវយកភាសាជាតិជាធំ យើងសូមអំពាវនាវដល់បងប្អូនរួមជាតិ

ហើយជាពិសេសដល់លោកគ្រូ អ្នកគ្រូ ឲ្យខំប្រមូលប្រជុំគ្នាផ្ដុំយោបល់ផ្ដុំគំនិតគ្នា រួបរួមជាមួយរាជរដ្ឋាភិបាល ជាមួយរដ្ឋសភា, រិះរកមធ្យោបាយគិតតែងសៀវភៅសិក្សាសព្វវិញ្ញាសារទាំងឡាយជាភាសាខ្មែរយើងឲ្យបានដើម្បីផ្សាយសុវិជ្ជាដល់ជនរួមជាតិយើង ដើម្បីឲ្យជនរួមជាតិយើងបានចេះដឹងពិតប្រាកដពីស្រុករបស់ខ្លួនក្នុងគ្រប់ផ្នែកទាំងអស់ ជាការឲ្យជនរួមជាតិបានក្ដីស្មាន បានយល់កាន់ជ្រៅវែងឆ្ងាយ នឹងអាចជួយជូនយោបល់ប្រសើរដល់រាជរដ្ឋាភិបាលក្នុងការកសាងប្រទេសជាតិមាតុភូមិឲ្យទៅកាន់សេចក្ដីចំរុងរឿង ។ ភាសាជាតិ កម្មវិធីជាតិ សៀវភៅជាតិ ប្រើទៅបានលទ្ធផលល្អ កាលណាគេប្រើរបៀបបង្រៀនល្អដែរ ។ របៀបបង្រៀនល្អគឺពន្យល់តាមសម្រួលដោយធ្វើឲ្យសិស្សយល់រហូតដល់ទៅឫសគល់នៃគំនិតខុស ឬគំនិតត្រូវដែលតែងកើតមានក្នុងការសិក្សា គឺមិនបង្ខំឲ្យគេយល់តាមតែខ្លួនម្នាក់ មិនប្រើវិធីវាយដំប្រចំណាក់ វិធីត្មះតិះដៀល រំលោភដោយកំហឹង ឬដោយអំណាចទេ គឺប្រើវិធីករុណាដើម្បីកសាង ដើម្បីកែប្រែ ហើយបើនឹងបង្រៀនវិញ គឺបង្រៀនឲ្យអស់ មិនលាក់លាបបំណោះភាគខ្លះទេ ។ ឯខាងការពិចារណាវិញ គេបង្ហាត់ឲ្យយល់ ឲ្យឃើញការខុសត្រូវ គឺបើគេនិយាយល្អដូចម្ដេច ឬសរសេរល្អដូចម្ដេច ត្រូវតែអនុវត្តន៍ឲ្យបាន ទោះយូរក្ដី ឆាប់ក្ដី ។ ធ្វើ

ដូច្នេះប្រយោជន៍ជំរុញដំណើរសង្គមឲ្យបានល្អ ។

ដូច្នេះហើយ គេត្រូវបង្ហាត់បង្រៀនឲ្យក្មេងបាន គោរពសុចរិតយុត្តិធម៌ ឲ្យមនុស្សជាតិ ឲ្យខ្ពើមនៅអំពើទុច្ចរិតញុះញង់ អំពើបំផ្លិចបំផ្លាញជាតិ ។

ខាងសិល្បៈ គេបណ្ដុះគំនិតឲ្យរាក់ទាក់នឹងមនុស្ស ខំរៀនការឲ្យមនុស្សបាន ជួបនឹងសុភមង្គល មនុស្សជួយបណ្ដុះទុក្ខមនុស្ស មនុស្សប្រឹងប្រែងជំរើន សកម្មភាពខ្លួនទៅប្រឆាំងនឹងការឃោរឃៅរបស់ជនជាតិ ដើម្បីយកផលល្អ មកចែកគ្នា ។

វិជ្ជាសាស្ត្រគេបង្រៀនឲ្យចេះជ្រៅជ្រះ ឲ្យមានគំនិតបង់វះរកបង្កើតវត្ថុ សំរាប់បំរើប្រយោជន៍រួម ប្រយោជន៍មនុស្សជាតិទាំងមូល ។ ម្ល៉ោះហើយគេ គ្មានទៅឃាត់ឃាំងស្រុកណាប្រទេសណា តូចក៏ដោយខ្សោយក៏ដោយ មិនឲ្យ គេមានទុស្សហកម្មនៅស្រុកគេទេ ។ គេមានតែពីស្មោះស្ម័គ្រជួយឧបត្ថម្ភ ថែមទៀត ។ ឯការដែលគេរកឃើញនោះទៀត គេពុំអាចយកមកប្រើដើម្បី កំហែងគំរាមបំផ្លិចបំផ្លាញមនុស្សសត្វគ្រប់ឡើយ ។ គេបំបែរទៅជាប្រយោជន៍ សុភមង្គលនៃមនុស្សទៅវិញ ដូចជាគេប្រើកម្លាំងបរមាណូដើម្បីឈាយភ្នំយក កន្លែងធ្វើស្រែចំការ ឬបង្កើតអគ្គិសនី ឬប្រើសម្លាប់មេរោគឃោរឃៅនៃជម្ងឺខ្លះ ។

ឯខាងនយោបាយវិញ គេបង្ហាត់ឲ្យជឿនយោបាយប្រៀបប្រួមប្រើការបះបោ

ជាផ្លូវផ្សះផ្សារ និយាយសម្រុះសម្រួល គឺនយោបាយអនុវត្តន៍លទ្ធិប្រជាធិបតេយ្យចំពោះប្រជាជនក្នុងស្រុក នឹងនយោបាយសន្តិភាពនៅក្រៅប្រទេស ។

វិជ្ជាទាំងអម្បាលមាណដែលប្រើតាមផ្លូវដូច្នេះ ហៅថាសុវិជ្ជា ។ សុវិជ្ជាបើកើតមាននៅស្រុកណាហើយ ស្រុកនោះនឹងចំរើន ជនជាតិស្រុកនោះចេះរួបរួមគ្នានៅក្នុងស្រុកធ្វើការកសាងឯករាជ្យអធិបតេយ្យភាពនៃប្រទេសជាតិមាតុភូមិ ព្រមទាំងធ្វើឲ្យជនជាតិស្រុកនោះរស់នៅជាសុខសាន្តក្នុងកិត្តិយសនឹងមង្គលសួស្តីផង ។

ដោយឃើញប្រយោជន៍ខ្លឹមសារនៃសុវិជ្ជាដូច្នេះ យើងសូមអំពាវនាវបងប្អូនរួមជាតិទាំងឡាយឲ្យខំខ្នះខ្នែងរួបរួមយ៉ាងជិតស្និទ្ធជាមួយនឹងរាជរដ្ឋាភិ - បាល ជាមួយរដ្ឋសភា ដើម្បីជំរុះទុរវិជ្ជា ដែលជាកំអែលអាណានិគមនិយម ហើយរកមធ្យោបាយនឹងចាត់វិធានការណ៍ យ៉ាងណា ឲ្យបានសាលារៀននៅស្រុកយើងបណ្តុះសុវិជ្ជាឲ្យកុលបុត្រកុលធីតាខ្លួនវិញ ។

(( =ចប់= ))

ជប្បុំហេតុផ្ដល់ការព្យាបាលនិង ហើយក្រោយមកយកទៅ ស្ថិតក្នុងផ្ទៃ

ជាដើមច្បាស់លាស់គេតែងតែព្យាបាលនិង ទម្រង់កន្លែងដែលច្បាស់លាស់ជាទីបញ្ចប់

ផ្ទៃពោះ ១ ចំពោះទារក ដែលត្រូវបានបង្កើតកើតមកក្នុងពិភពលោក

ពេលកើតរួចហើយគឺ និងពិនិត្យមើលទារក ហើយការពារកុមារបានឲ្យបានគង់វង្ស

ក្នុងការថែទាំរាងកាយរបស់ទារកដែលកើតមកក្នុងប្រទេសជាតិហើយកើតមកនូវកុមារនោះ

អាចនឹងទទួលបានការថែទាំសុខភាពល្អប្រសើរឡើងបាន ខ្លួន

៣ និងកុមារព្យាបាលមនសិក

ការថែទាំកុមារជានិច្ច ដែលត្រូវការនូវការបង្កើតសុខភាពល្អជាចាំបាច់

ដោយសារតែកុមារជាមនុស្សដែលត្រូវការការថែទាំដោយយកចិត្តទុកដាក់ជាពិសេស

មកពីមាតាបិតាដែលជាអ្នកថែរក្សា កុមារនោះឲ្យបានល្អ ការពារកុមារ

ក្នុងការរស់នៅប្រកបដោយសុខភាព និងការថែទាំសុខភាពកុមារទាំងអស់

១ ក្នុងពេលកុមារកើតមកក្នុងពិភពលោកនេះ ១

((–=០០=–))

# បញ្ហាអនាម័យ

## ម្ដេចបានត្រូវបំផ្លាញសត្វកណ្ដុរ

សត្វលោកចែកជាពីរពួក

១) សត្វលោកដែលមានសតិសម្បជញ្ញៈ (គឺមនុស្ស)

២) សត្វលោកដែលប្រកបដោយសភាវៈគំគិត (សត្វតិរច្ឆាន)

មនុស្សដែលមានសតិសម្បជញ្ញៈ សំរាប់បំភ្លឺឲ្យស្គាល់ផលល្អ-អាក្រក់ មុននឹងធ្វើការអ្វីនិមួយ ៗ តែងតែត្រិះរិះពិចារណារកហេតុ ផលអាក្រក់ល្អ បំពោះអំពើដែលខ្លួនត្រូវប្រព្រឹត្ត ៗ បំណែកឯសត្វតិរច្ឆាន ដែលមានតែ សភាវៈគំនិត គឺស្ដាប់បង្គាប់តែការបំណង់ . . .ធ្វើការអ្វីក៏ដោយ គឺសំរាប់តែ ឲ្យរស់តែមួយមុខ ទោះជាអំពើនោះអាក្រក់គឺបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ រហូតដល់ទៅរំលាយជីវិតសត្វដូចគ្នា ឬមនុស្សក៏ដោយ ៗ ដើម្បីនឹងពន្យល់ឲ្យឃើញច្បាស់នូវអាកប្បកិរិយានៃសត្វតិរច្ឆានខ្ញុំសូមយកបញ្ហាសត្វកណ្ដុរមកដោះស្រាយដូចតទៅ :

គេបានឲ្យការថា ចំនួនកណ្ដុរមានស្មើគ្នានឹងចំនួនមនុស្សក្នុងសកល-លោក ។ បើប្រសិនជាគ្មានបង្កើតវិធីដើម្បីនឹងបំផ្លាញវានោះ ចំនួនកណ្ដុរត្រូវតែលើសចំនួនមនុស្ស ។ ហេតុអ្វីបានតែត្រូវសម្លាប់សត្វកណ្ដុរ?

១)កណ្ដុរជាសត្វនាំជម្ងឺ ( មានជម្ងឺប៉េស្ដិ៍ជាដើម នេះដោយសារចៃរបស់វា)

២)កណ្ដុរជាសត្វចង្រៃ កាត់, កកេរទ្រព្យសម្បត្តិ នឹងស៊ីគ្រឿងបរិភោគ ( នៅក្រុងប៉ារីសគេស្ទង់ទៅឃើញថា កណ្ដុរបានស៊ីគ្រឿងបរិភោគអស់ ១៨០.០០០គីឡូក្រាមក្នុង១ថ្ងៃ ) ។

តមកខ្ញុំសូមពណ៌នាអំពីជីវភាពនៃសត្វកណ្ដុរដូចតទៅ:

កណ្ដុរចែកជាពួក:

ក) កណ្ដុរពណ៌ប្រផេះឬកណ្ដុរលូទឹក

ខ) កណ្ដុរខ្មៅ ឬកណ្ដុរជង្រុកស្រូវ

គ) កណ្ដុរមេះ (ឈ្មោះ ?)

ក) កណ្ដុរប្រផេះ

កណ្ដុរប្រផេះមានទំហំប្រហែល៤០ទៅ៥០សង្ទីម៉ែត្រ (គិតពីចុងច្រមុះទៅចុងកន្ទុយ) ពណ៌ប្រផេះស្វាទំលើខ្នងនឹងពណ៌ប្រផេះត្រង់ពោះ ។ កណ្ដុរពួកនេះមិននៅក្នុងផ្ទះទេ គឺនៅជិតលូបង្ហូរទឹកសំអុយនឹងបាទផ្ទះ (កន្លែងផ្ទះបាយដែលនៅ

ក្រោមបំផុត សំរាប់ដាក់អីវ៉ាន់ផ្សេងៗ)ៗ វាកាយរូងក្នុងដី, រូងនោះមិនសូវជ្រៅ តែវែងឆ្ងាយទីងមានរន្ធបង្ហុយច្រើន ជាកិច្ចសំរាប់ងាយគេចវេះ ៗ វាពូកែហែលទឹកនិងមុជទឹកជាទីបំផុត ( ហេតុនេះបានជាគេឲ្យឈ្មោះថាកណ្ដុរលូបង្ហូរទឹកសំអុយ) តែមិនប្រសប់ខាងឡើង ៗ វាមានទម្ងន់១៨០ក្រាម, ត្រូវការអាហារសំរាប់ចិញ្ចឹមជីវិតវា ៦០ក្រាមក្នុង១ថ្ងៃ ហើយមិនអាចអត់អាហារលើសពី៤៨ម៉ោង ៗ ហេតុនេះហើយបានជាវាមានគំនិតចេះលួចជញ្ជូនគ្រឿងអាហារទៅលាក់ទុកសំរាប់ដល់គ្រាក្រ ៗ ធ្មេញវាដែលចេះតែដុះបន្តៗគ្នានោះ មិនគ្រាន់តែសម្រាប់ទំលាយគ្រឿង-វត្ថុដែលបិទបាំងផ្លូវវាដើម្បីទៅរកអាហារតែប៉ុណ្ណោះទេ វាសំរាប់ទាំងកកេរខាំស្បែក ឆ្អឹង ផ្ទាន ឈើ សំណារ ខ្សែភ្លើងអគ្គិសនី ដែលអាចបណ្ដាលឲ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ (ដូចជាខ្សែដែលភ្ជាប់នៅក្នុងកប៉ាល់ហោះជាដើម) ៗ

កណ្ដុរញីកាលបើវាស៊ីអាហារគ្រប់គ្រាន់ ហើយកុំឲ្យមាននរណាទៅបៀតបៀនវា ៗ អាចបង្កើតកូន៣ឬ៤ដងក្នុង១ឆ្នាំ ៗ កូន១ដងៗបាន៧ដល់១១ ៗ កូនកណ្ដុរអាយុបាន១ខែវាអាចចេញរកស៊ីខ្លួនឯងបាន អាយុបាន៣ខែវាអាចបង្កើតកូនបាន ៗ អាយុកណ្ដុរបានត្រឹម ២ ឬ ៣ ឆ្នាំតែប៉ុណ្ណោះ ៗ ដោយមានការអត់អាហារ ជម្ងឺ ការប្រឆាំងពីមនុស្សនិងសត្វ

ដទៃទៀត នឹងវាងកណ្ដុរគាវ៉ា អស់នេះជាហេតុ១យ៉ាងគាប់ប្រសើរដើម្បីកុំឲ្យចំនួនកណ្ដុរមានច្រើនហួសកំរិត ព្រោះបើវាមានចំនួនច្រើនគ្រោះថ្នាក់មកលើមនុស្សក៏មានកំរិតឡើងតាមហ្នឹងដែរ ។

កណ្ដុរប្រផេះនេះមានវ័យធ្ងាតពូកែណាស់ ខ្សែលួសអគ្គិសនីមិនអាចធន់វាបានទេ គ្រឿងបំពុល មិនអាចទៅប្រឡំវាបានដោយងាយ ។ កាលបើមានជម្ងឺសត្វវារត់ចោលកន្លែងរបស់វា ដើម្បីទៅរកកន្លែងថ្មីដែលសុខសាន្តត្រាណ ។ ក្នុងពេលនេះវាមុខតែជួមយានជំនិះរបស់មនុស្សដែលជាស្ពានសំពៅចងទៅកាន់ទីកន្លែងថ្មី, នេះជាហេតុមួយធ្វើឲ្យជម្ងឺឆ្លងពីកន្លែងមួយទៅកន្លែង១បាន (មានជម្ងឺប៉េស្ដិជាដើម) ។ បើនៅកន្លែងរបស់វាដែលធ្លាប់នៅ អត់អាហារ, វាមិនសុខចិត្តនៅលំបាកវេទនាទេ វាបង្កើតជាក្រុមជាហ្វូងត្រេចដើរទៅរកទីកន្លែងណាដែលមានអាហារ ។ តែកុំប្រឡំថាវាដើរចោលទីកន្លែងចាស់របស់វាដាច់ខាតនោះឡើយ ព្រោះវាមុខតែត្រឡប់វិលមកវិញកាលបើវាដឹងថានៅកន្លែងចាស់របស់វាមានអាហារបរិបូណ៌គ្រប់គ្រាន់ ។

២– ឥកណ្ដុរខ្មៅ:– កណ្ដុរខ្មៅប្រវែង ៣៦ ទៅ ៤៤ សង់ទីម៉ែត្រ កន្ទុយធំ វែងជាងខ្លួន ត្រចៀកស្ដើងធំជាងពាក់កណ្ដាលក្បាល ម្រាមជើងជាប់គ្នាដូចជាម្រាមជើងកណ្ដុរប្រផេះ ។ កណ្ដុរនេះត្រឡប់ទៅនៅស្រុក

ស្រែចម្ការវិញ ដោយសារចាញ់ដៃកណ្ដុរក្រុងវាមកកកតត្បាត ។ វាពូកែខាងឡើង ប៉ុន្តែប្រសប់ខាងរកទីកន្លែងជ្រក, ទោះជាផ្ទះច្រើនជាន់ក៏ដោយ ។ ដូច្នេះវាអាចនាំចៃរបស់វាទៅខាំមនុស្សតាមអំពើចិត្តរបស់វា ។

៣– កណ្ដុរល្មុះ — កណ្ដុរនេះមិនសូវមានគ្រោះថ្នាក់អ្វីជាធំដុំ ក្រៅអំពីការបំផ្លិចបំផ្លាញរបស់ប្រើប្រាស់និងម្ហូបចំណីរបស់យើង ។ វាមានប្រវែង ១៧ ទៅ ១៩ សង់ទីម៉ែត្រ ពេមប្រផេះសណ្ដែកបាយពីខាងលើខ្លួន ពណ៌ប្រផេះត្រង់ពោះ ។ វារស់នៅក្នុងផ្ទះសម្បែងកន្លែងគៀនគោះ ដែលជាទីជ្រករបស់វា ។

## វិធីប្រឆាំងនឹងសត្វកណ្ដុរ

១) វិធីការពារ

ក) វិធីការពារកុំឲ្យកណ្ដុរចូលក្នុងផ្ទះបាន

គឺសង់ផ្ទះតាមរបៀបសម័យ ដោយបិទប្រហោងកុំឲ្យកណ្ដុរចូលបាន ឬប្រើរបៀបកុំឲ្យវាឡើងទៅលើផ្ទះបាន ។

១) វិធីដោយបង្អត់អាហារនិងទឹក

ការចោលសម្រាមឬគ្រឿងអាហាររាត់រាយ ជាកិច្ចសម្រាប់ឲ្យកណ្ដុររស់នៅបានដោយងាយ ។ ចំពោះរឿងនេះ យើងធ្វើបានដោយលំបាកជាទី

បំផុត ព្រោះយើងមិនទាន់រៀបចំស្រុកទេសបាន ដោយខ្វះតិកនិកនិងសម្ភារៈផ្សេង ៗ ។

២) ការប្រឆាំងដោយប្រើវិធីបំផ្លាញ

ក) ការចាប់កណ្ដុរ

- ដោយប្រើឆ្មា
- ដោយប្រើឆ្កែ
- ដោយប្រើអន្ទប់

១) ប្រើគ្រឿងបំពុល ។

រឿងបញ្ហាកណ្ដុរនេះជាបញ្ហាលំបាកនឹងដោះស្រាយជាទីបំផុត ព្រោះនៅកន្លែងខ្លះវាអាចនៅសុខសាន្តគ្មាននរណាទៅបៀតបៀនវាបាន ហើយវាចេញដើររកស៊ីនៅវេលាយប់ដែលពេលប្រកបដោយកុសលរបស់វា ។

---

“ ក្នុងគ្រាក្រ ការថយកម្លាំងទឹកចិត្ត ជាលក្ខណៈបុរសគំរក់ ” ។

( ញ៉ង-ខាត់ )

# បញ្ហាសេដ្ឋកិច្ច

## „ត្រែត ,, (Traite)

---

នៅក្នុងចំណោមអ្នកជំនួញ គេតែងឮនិយាយថា ស៊ីញេត្រែត សងថ្លៃត្រែត ៗ អ្វីទៅដែលហៅថាត្រែតនោះ?

ក្នុងការលក់ដូរ អ្នកទិញមិនទៀងតែមានប្រាក់គ្រប់គ្រាន់ដើម្បីចេញថ្លៃដល់ដៃភ្លាម ៗ នោះទេ ។ បើទុកជាមាន ជួនកាលត្រូវការទុកប្រាក់នោះធ្វើជាដើមទុន សម្រាប់ចាយចំពោះការផ្សេង ៗ ទៀតក៏មាន ។ ចំណែកអ្នកលក់ តែងតែចង់បានប្រាក់ឆាប់ ៗ នឹងយកទៅទិញមកលក់ទៀត ។

ដើម្បីឲ្យបានគាប់ចិត្តដល់អ្នកទាំងពីរពួកនេះ គេមានគំនិតបង្កើតលិខិតមួយបែបហៅថា ត្រែត គឺជាសេចក្ដីបង្គាប់ពីអ្នកលក់ទៅអ្នកទិញឲ្យសងប្រាក់មកខ្លួនអ្នកលក់វិញ ឬទៅអ្នកឯណាម្នាក់ទៀត ក្នុងរយវេលាដូចកម្រិតក្នុងលិខិតនេះ ដែលអ្នកទិញចុះហត្ថលេខា ទទួលយល់ព្រម ។ ជួនកាល

អ្នកលក់តម្រូវឲ្យមានអ្នកធានាទៀត ដែលចុះហត្ថលេខាជាមួយផង ។

កាលបើធ្វើដូច្នេះហើយ អ្នកទិញបានបំណោញបន្ថយពេលដែលត្រូវសងប្រាក់ទៅអ្នកលក់ ចំណែកអ្នកលក់វិញ បើប្រញាប់ត្រូវការប្រាក់ចាយ អាចយកសន្លឹកត្រែតនោះទៅបំណាយ ឲ្យធនាគារណាមួយដែលគេមានសេចក្ដីទុកចិត្ត ។ ធនាគារនោះចេញប្រាក់ឲ្យមកអ្នកលក់ជាមុន តែគាត់យកប្រាក់ខ្លះ សម្រាប់ជាការប្រាក់ដែលចេញឲ្យ តាមធម្មតាធនាគារព្រមទទួលតែសន្លឹកត្រែតណាដែលមានហត្ថលេខាពីរយ៉ាងតិច ហើយរយៈពេលដែលត្រូវសងប្រាក់នោះ កុំឲ្យហួសពី៩០ថ្ងៃ ។ អ្នកលក់បើមិនយកត្រែតលក់ទៅឲ្យធនាគារទេ អាចទុកផ្ទេរឈ្មោះ ទៅឲ្យមេបំណុលខ្លួនឯងណាម្នាក់ទៀតក៏បានបើគេយល់ព្រម ។ របៀបបែបនេះមានប្រើជារឿយៗដែរ ជួនកាលផ្ទេរពីម្នាក់ទៅម្នាក់ជាច្រើនគ្នា មុននឹងដល់ពេលដែរត្រូវទារប្រាក់ ចំណែកអ្នកទទួលបន្តនេះ ក៏អាចយកត្រែតនេះទៅលក់ឲ្យធនាគារបានដូចគ្នា ។

កាលណាដល់រយៈពេលដែលត្រូវសងប្រាក់ អ្នកទិញដែលជាកូនបំណុលមុនដំបូង ត្រូវបំរុងប្រាក់ទុកសងអ្នកដែលទទួលត្រែតក្រោយគេបង្អស់ជាដាច់ខាត ជួនកាលចេញសងខ្លួនឯង ជួនកាលឲ្យធនាគារណាមួយគេចេញសងជួសឲ្យ ។ កាលណាកូនបំណុលមិនទាន់មានប្រាក់សងអ្នកម្ចាស់

ត្រែតបុងក្រោយទេ  គេអាចធ្វើត្រែតមួយជាថ្មី ។ បើមិនព្រមទេតោងតែក្នុងរយៈ៤៨ម៉ោងប្តឹងទៅអាជ្ញាសាលា ធ្វើសំបុត្រកត់សំគាល់ រួមការប្រាក់ពីនាក់ដែលផ្ទេរត្រែតមកឲ្យខ្លួន បើអ្នកនេះគ្មានប្រាក់សងតោងដេញឡើងរហូតដល់អ្នកលក់ ដែលចេញត្រែតពីដំបូងដៃ អ្នកទាំងនេះត្រូវទទួលខុសត្រូវតៗគ្នាយ៉ាងដូច្នេះ ។

ការដែលមិនបានសងប្រាក់ឲ្យទាន់ពេលវេលា បណ្តាលឲ្យមានទោសធ្ងន់ៗ ដើម្បីនឹងការពារអ្នកដើមបំណុល ច្បាប់បានបញ្ញត្តិដាក់ទោសជាទម្ងន់ដូចជាតម្រូវឲ្យដាក់ឡាយឡុងទ្រព្យសម្បត្តិ ជាដើមចំពោះកូនបំណុលណាដែលរកប្រាក់សងថ្ងៃត្រែតដែលខ្លួនបានចុះហត្ថលេខាយល់ព្រមពីមុនមក ។

ហេតុនេះ បើអ្នកឯណាទិញឥវ៉ាន់បណ្តាក់គេហើយបានចុះហត្ថលេខាលើត្រែតទទួលសងគេពេលណា តោងតែប្រុងប្រៀបរកប្រាក់សងគេទៅពេលវេលាដែលបានចុះសន្យា ។

---

“ បុគ្គលពុំគប្បីចងមិត្រសម្លាញ់ ឬ ចងស្ពានមេត្រីជាមួយមនុស្សទុរជនឲ្យ
សោះ ពីព្រោះមនុស្សនោះប្រៀបដូចធ្យូង បើនៅក្តៅវារលាកដៃ បើរលត់
ហើយ វាប្រឡាក់ដៃ ” ។

( ប៉ាង-ខាត់ )

# អត្តពលកម្ម

អត្តពលកម្ម ជាវិធីមួយដើម្បីអប់រំប្រាណឲ្យបានថិតថេរនឹងឲ្យចំរើន ៗ មនុស្សជាតិបើអត់ការអប់រំនឹងអន្តរាយ មនុស្សជាតិបើរកការចំរើនគ្មានក៏ វិលទៅរកការអន្តរាយវិញដែរ ។

ប្រាណមានជីវិតត្រូវការធ្វើសកម្មភាពតាំងពីដើមកំណើត លុះអស់ជីវិតទៅវិញ ។ ដូច្នេះមនុស្សសត្វដើម្បីនឹងរស់ត្រូវតែធ្វើការ, ដូចជាសត្វក៏ត្រូវប្រើកម្លាំងកាយសុទ្ធ ៗ យកទៅចិញ្ចឹមជីវិត ។ សត្វណាអត់ខ្សោយដោយកម្លាំងកាយក៏បាត់អស់ពីផែនដី ឬក៏ទៅជាសត្វសម្រាប់ចិញ្ចឹមមនុស្ស គឺសត្វពាហណៈទាំងឡាយ ។ ដូច្នេះការរស់ឬស្លាប់សម្រេចត្រង់ប្រាណ ។

លើសពីសត្វ មនុស្សមានបញ្ញានឹងសីលធម៌ដែលជាការប្រសើរក្រៃលែង ប៉ុន្តែមនុស្សច្រើនតែបណ្តែតបណ្តោយឲ្យកម្លាំងកាយ បញ្ញាទៅគ្របសង្កត់សីលធម៌ដ៏ប្រសើរ ហើយយកសីលធម៌មិនស្អាតទៅឲ្យវិញ ដោយ

មនុស្សជាប់មកជាមួយខ្លួននូវសភាវគំនិត ដែលធ្វើឲ្យសតិសម្បជ្ជៈប្រាស ចាកចេញចោល ។

ការៈដ៏សំខាន់របស់អត្តពលកម្មគឺធ្វើមនុស្សដែលអន់ខ្សោយ ឲ្យបានថិតថេរមនុស្សល្អមឲ្យបានចំរើនទៅដោយលក្ខណសម្បត្តិ៣យ៉ាងគឺ:

១) ឲ្យបានប្រាណបានសុខ, សាច់ដុំធំដើម្បីទប់ទល់អាកាស នឹងជម្ងឺគ្រប់បែបគ្រប់យ៉ាង

២) ឲ្យខួរក្បាលបានស្អាត នឹងបង្កើតបញ្ញាស្មារតីឲ្យបានចំទូលាយ

៣) ឲ្យបានសីលធម៌ល្អ បេះស្រឡាញ់មនុស្សជាតិ ដោយខំស្វែងរកផលប្រយោជន៍ឲ្យមនុស្សជាតិ ។

អត្តពលកម្មជាក្បួនសំរាប់ធ្វើឲ្យមានសុខភាព ដោយមានខ្លួនមាំមួនសាច់ដុំពូក មានកំលាំងក្រាស់ នឹងទប់ទល់នឹងជម្ងឺផ្សេង ៗ វិធីនេះមិនមែនប្រទាំងនឹងបញ្ញា ឬសីលធម៌ល្អទេ បើមានកម្លាំងហើយខ្វះបញ្ញានឹងសីលធម៌ នឹងទៅជាសត្វទៅវិញ ។

បើមើលសើរៗទៅគេឃើញថាប្រហែលជាខុសគ្នា តែបើពិចារណាឲ្យច្បាស់ឲ្យជ្រៅទូលាយទៅច្បាស់ជាស្របគ្នាប្រាកដណាស់, តាមការសង្កេតរបស់បណ្ឌិតខាងទស្សនវិជ្ជាសកលលោក;«ស្មារតីល្អរស់នៅក្នុងប្រាណសុខ»

លោកស្ពិនស៊ែរមានប្រសាសន៍ថា: «រស់បានក្នុងលោកនេះ មានតែសត្វមាំមួនទេ ហើយជាតិនិមួយៗបានចំរើននោះ លុះតែមានមាឌមាំមាំ» ។ «បាយឆ្ងាញ់ឈាមរត់ស្រួល មានអាកប្បកិរិយារីករាយសប្បាយរាល់ៗពេល ជាសម្បត្តិខាងក្រៅមួយរបស់មនុស្សដែលរកប្រៀបប្រដូចគ្មាន» «អ្នកណាស៊ីដោយឥតធ្វើការ គឺស៊ីដោយសារអ្នកដទៃ» ។

មនុស្សនឹងទៅជាមនុស្សពេញនោះ គឺដោយសារតែការអប់រំ ។ ការអប់រំជាឫសម្ពជាមូលដ្ឋាននោះ គឺការហាត់ប្រាណ (អត្តពលកម្ម) ។ ធ្វើអត្តពលកម្មដើម្បីឲ្យបានសុខក្នុងលោកនេះ ដើម្បីធ្វើការចិញ្ចឹមប្រាណ ដោយមនុស្សធម៌ ។ លុះដោយខំធ្វើប្រាណឲ្យមាំ ឲ្យឈាមមេរបស់យើងមានសមត្ថភាព នឹងការពារទប់ទល់នឹងមេរោគបានដោយងាយ ។ សុខដោយខំធ្វើឲ្យសាច់ដុំពួកដើម្បីរកអាហារនិងសម្ភារៈ ផ្សេងៗមកលៀងជីវិត ឲ្យបានសមរម្យជាមនុស្ស ។ ដូច្នេះអត្តពលកម្មជាអនាម័យជាវិធីនាំមនុស្សឲ្យធ្វើការឲ្យបានចំរើន ។ ក្រៅពីសេចក្តីសុខនិងធ្វើការបានច្រើន អត្តពលកម្មធ្វើឲ្យមនុស្សបានទៀត ឲ្យស្មារតីរហ័សរហួន ឲ្យប្រាជ្ញាបានស្អាតល្អ ដូចលោក «ផ្លាតុង» ពោលថា: «ទស្សនិយភាពដែលប្រសើរនោះ គឺជាស្មារតីនឹងប្រាណប្រកបទៅនឹងសុខដុំ» ។

តាមប្រវត្តិសាស្ត្ររឿងៗមករបស់មនុស្ស អត្តពលកម្មមានឡើងដោយជាប់នឹងជំនឿនឹងលទ្ធិផ្សេងៗនឹងសាសនាក្លាយដោយល្បែងផ្សេងៗព្រោះល្បែងជាបំណងធម្មតារបស់មនុស្សព្រោះមនុស្សត្រូវការសប្បាយរីករាយ ៗ ជាតិណាសង្គមណា ដែលមិនយល់ផលប្រយោជន៍ការហាត់ប្រាណជាតិនោះ សង្គមនោះក៏អន់ខ្សោយជាដរាប ហើយរកសេចក្តីសប្បាយតែពីល្បែងមិនស្អាត ៗ ប្រាណក៏ថយកម្លាំងពលំការធ្វើក៏បានតិច យូរៗទៅជាតិនោះ សង្គមនោះ ក៏រលាយបាត់ពីលោកដោយការអន្តរាយវាមកគ្របសង្កត់គ្រប់បែបគ្រប់ផ្លូវៗមនុស្សម្នាក់ៗបានសុខហើយធ្វើការបានត្រឹមត្រូវសង្គម មនុស្សនោះមាំហើយចំរើន ៗ

បណ្ឌិតសម័យថ្មីថា « ធ្វើផ្ទះពេទ្យច្រើនសម្រាប់ប្រឆាំងមេក្រមីធ្វើអ្វី បើមិនប្រាប់វិធីឲ្យគ្នាបានដឹងមុនដើម្បីការពាររោគ បើចង់បន្ថយផ្ទះពេទ្យនឹងសំណាល់មនុស្ស តោងតែបើកសាលាដើម្បីអប់រំធ្វើឲ្យយុវជនធាត់ធំមាំមួន »

(មានត)

---

នាងដាទៅឲ្យលោកគ្រូពេទ្យពិនិត្យ ។

— ខ្ញុំឈឺចង្កេះ, ឈឺក្រពះ, ឈឺខ្នង

— បើអញ្ចឹងដោះសម្លៀកបំពាក់ចេញ !

(លោកគ្រូពេទ្យមានប្រសាសន៍)

— ឲ្យខ្ញុំដោះសម្លៀកបំពាក់ ? ហេតុអ្វី ? លោកមិនជឿខ្ញុំទេ ?

# សកម្មភាពនិស្សិតក្នុងសកលលោក

យើងសូមអភ័យទោសដល់បងប្អូនអ្នកអានពិសេសជាប់និស្សិតសិស្សានុសិស្ស ដោយយើងពុំបានលើកសកម្មភាពនៃនិស្សិតពីខែមុន ដូចជាសន្និសីទនៅបានឌុង រវាងនិស្សិតអាហ្វ្រិក-អាស៊ី ដូចជាការប្រជុំក្រុមកាយវិទូសាកលលោក មកអធិប្បាយជូន ។ ការខ្វះខាតនេះបណ្ដាលមកពីទស្សនាវដ្ដីយើងទើបនឹងកើតថ្មីផង មកពីយើងខ្វះឯកសារផង ។ លំដាប់តទៅនេះយើងសូមលើកយកសកម្មភាពនៃនិស្សិតសាកលលោកក្នុងខែនេះមកអធិប្បាយជូន ។

នៅក្រុងប្រាគ (ឆេកូស្លូវ៉ាគី) សមាជទី៤ នៃនិស្សិតអន្ដរជាតិ ដែលបានបើកសម័យប្រជុំនៅថ្ងៃទី២៦ខែតុលាមុននេះ បានបញ្ចប់សម័យប្រជុំនៅថ្ងៃទី២ខែកញ្ញាឆ្នាំ១៩៥៦ ។ នៅក្នុងសមាជមានប្រតិភូចំនួន៦០០នាក់ដំណាង៨០ប្រទេស ។

សមាជបានសម្រេចសេចក្ដីសម្រេចខ្លះដូចតទៅ:

ទី១.- តាមសេចក្ដីស្នើរបស់សហពន្ធជាតិនៃនិស្សិតបារាំងនិងសហពន្ធនៃ

និស្សិតទុយនីស៊ី សមាជបានសម្រេចនឹងបើកប្រជុំសន្និសិទមួយនៅក្រុងប៉ារីស ដើម្បីប្រមូលធ្វើឲ្យមានឯកភាពក្នុងចលនានិស្សិតអន្តរជាតិឡើងវិញ រវាងសហពន្ធនិស្សិតអន្តរជាតិនឹងនិស្សិតអន្តរជាតិ ។

តាមសេចក្ដីស្នើរបស់គណៈកម្មាធិការសារពត៌មានសមាជបានសម្រេចនឹងបង្កើតការិយាល័យអន្តរជាតិនៃសារពត៌មានរួមមួយ រវាងអង្គការទាំង២នេះ ។

ទី៣.–ប្រទេសបារាំងត្រូវបានចាត់ជាកន្លែង នឹងជាអ្នករៀបចំធ្វើបាតុកម្មខាងកីឡាសាកលលោករវាងនិស្សិត នឹងបាតុកម្មខាងវប្បធម៌ ។

ដើម្បីឲ្យយល់នូវចលនានិស្សិតសកលលោក យើងសូមអធិប្បាយដោយសង្ខេបនូវប្រវត្តចលនានេះ ។ មុនដំបូងយើងត្រូវដឹងថាក្នុងប្រទេសនិមួយៗនៅគ្រប់សាលាជាន់ខ្ពស់ គ្រប់មហាវិទ្យាល័យនិស្សិតតែងប្រមូលផ្ដុំជាសមាគម ។ សមាគមតូចៗ នេះដែលមានគ្រប់សាលាបានប្រមូលផ្ដុំជាសហពន្ធសមាគមជាតិមួយដើម្បីជាដំណាងនិស្សិតក្នុងប្រទេសនិមួយៗ ។ ដូចជាសហពន្ធជាតិនៃនិស្សិតបារាំង នៃនិស្សិតអង់គ្លេសជាដើម ។ ល ។

កាលពីរួចបម្បាំងលើកទី២ ដោយឃើញការវេទនាការអន្តរាយដល់និស្សិតជាខ្លាំង និស្សិតនៅប្រទេសអឺរុបជាច្រើនបានប្រជុំគ្នានៅក្រុងឡុនដុន (ពជធានីអង់គ្លេស) ដើម្បីនឹងបង្កើតអង្គការនិស្សិតមួយៗ គោលបំណងនៃអង្គ

ការនេះគឺធ្វើឲ្យនិស្សិតស្គាល់គ្នាឲ្យជិតស្និទ្ធឲ្យរាប់អានគ្នា ដើម្បីខាខាំងកុំឲ្យមាន នៅថ្ងៃក្រោយ ។ គេបានសម្រេចក្នុង២ឆ្នាំម្ដងធ្វើមហាសមោសរ យុវជន ។ ( Festival ) មហាសមោសរ លើកទី១បានចាប់ធ្វើក្រុងឡុងដននៅឆ្នាំ ១៩៤៧ ។ រាល់ឆ្នាំគេធ្វើសន្និសីទមួយជួបជុំសមាជិកដើម្បីទឹងប្ដូរការពិសោធ ដើម្បីធ្វើឲ្យនិស្សិតបានជូរក្នុងការស្វែងរកបំណោះវិជ្ជា ។ អង្គការនេះឈ្មោះ ហៅថាសហពន្ធនិស្សិតអន្តរជាតិ ។ សហពន្ធនេះមានសមាជិកគ្រប់ប្រទេស មិនថាប្រទេសតូចតាចប្រទេសបំណុះគេទេ ។ តែអង្គការនេះមិនបានមូល គ្នាទេ នៅឆ្នាំ១៩៥១ មានសមាជិកប្រទេសអឺរ៉ុប ខាងលិចខ្លះលាចេញហើយ មកបង្កើតអង្គការមួយទៀតដែលហៅថាសន្និសីទនិស្សិតអន្តរជាតិ ។ នៅក្នុង អង្គការក្រោយនេះមាននិស្សិតបារាំងអង់គ្លេស អាមេរិកជាមេគំនិត ។

ចំនួនសមាជិកក្នុងអង្គការទាំងពីរនេះមានដូចតទៅ: សហពន្ធនិស្សិតអន្ត-រជាតិមានសមាជិកចំនួនប្រហែល៨០ប្រទេស សន្និសីទនិស្សិតអន្តរជាតិមាន ប្រហែល ៣០ ប្រទេស ។

សហពន្ធនិស្សិតអន្តរជាតិជាគណប្រតិភូមួយដែរក្នុងអង្គការអុយណេស្កូ យើងបានដំណឹងទៀតថា មហាសមោសរយុវជន ឆ្នាំ១៩៥៧ នឹង

ធ្វើនៅក្រុងមួយៗ នៅក្នុងពិធីបុណ្យនោះគួរតែយុវជននិស្សិតខ្មែរដែលជាពលរដ្ឋប្រទេសឯករាជ បានរួមប្រាស្រ័យជាមួយផង ដើម្បីនឹងផ្សាយនូវសិល្បៈខ្មែរ នូវអារ្យធម៌ខ្មែរ ៗ

---

## ខ្លួនចាស់ ចិត្តក្មេង

អ្នកខ្លះខ្លួនចាស់ ចិត្តនៅក្មេង
នរណាពោលលេង ថាមើលងាយ
គេហៅថា តា-តា យាយ-យាយ
មុខគ្មានរីករាយសប្បាយម្តង ។
គេហៅថា នាង ឬ អ្នកបង
អរក្រៃកន្លងឥតឧបមា ។

( សោម-ឡុប )

ស្រង់ពីទស្សនាវដ្តីកម្ពុជសុរិយា

# កំណាព្យខ្មែរ

## ក្មេងឆ្លូតស្រែតាដើង

ទេសភាពយ៉ាងឯក តែមិនបំភ្លេក
ក្នុងដែនខេមរ ទេសភាពទាញចិត្ត
ឲ្យពិចារណា គឺជោគវាសនា

បុត្រខ្មែរមួយភ្នក់ ៗ

រូបកាយស្គមស្គាំង មុខស្លេកស្លុតស្លាំង
ពោះដូចដូងក់ ដងខ្លួនកំប្រឹង
ស្បែកសឹងគ្រីក្ដក់ ព្រោះដេកមិនលក់

មូស-ខ្យល់-ទុក្ខា ៗ

ដំណើរស៊ីដេក គួរអាណោចពេក
ក្រោកតាមមាត់ផ្សារ រស់ដោយសំណល់

ខ្វាយខ្វល់ដូចខ្លា ឃ្លានជាធម្មតា

អត់ជាប្រក្រតី

តាមដោយផ្ទះហាង កុកម៉េង-កុងសាង

អស់លោកប្រុសស្រី អូប៉ែល ក្តីមុត

កែងចោតកែងខ្លី កែកពយក្អេបក្អី

វេទនាខ្វៃខ្វាត់ ៗ

ខ្វះមានតែអាវ ខោប៉ះ ដូចបាវ

បិទបាំងតាមអត់ ដៃអោបប្រអប់

សំណាប់ផ្គង់ផ្គត់ រស់ដោយរន្ធត់

ដូតស្បែកជើងលោក ៗ

ពីរវៀលមួយគូ សន្ទ្រុតស៊ូ

គ្រាន់បរិភោគ ជួនជាថ្ងៃស៊ីយ

ដេកសោយទុក្ខសោក ព្រោះឃ្លានទ្បៀពោត

យាយីអាត្មា ៗ

ថ្ងៃមួយថ្ងៃពីរ រោគាព្យាធិ

ញាំញីយ៉ាងក្លា រស់ស្លាប់ដូចសត្វ

អត្តខាត់អស្ចារ្យ    កណ្តាលទីផ្សារ

ក្រុងកម្ពុជា ៗ

នេះគឺខ្មោចផ្សារ    សង្គមបញ្ហា

ដែលលោកមិនមា    រួសរាន់ដោះស្រាយ

រំសាយទុក្ខគ្នា    រួបរួមការពារ

លើកជីវភាពក្រ ៗ

---

— ហេតុអ្វីក៏លោកយប្រែពន្ធបី ?

— មកពីខ្ញុំមានសមុទការ !

ចៅក្រមឮឆ្លើយឡោះ អស់សំណើច ដោយនឹកឃើញច្បាប់តុលាការ

ពុំបានអនុញ្ញាតឲ្យដាក់លោកមែន ៗ

ក្រុមចិនាកណ្ដាល ព្រះភក្ត្រទេវ្ចុន

៥ ជាមួតសិក្ស

ញាណមមិត្ត ក្តុំង ទ្រង់នេះមា

មសម្រះជាន់តកាក្ស ជានិមិតលោកហាវរ

ក្រោលយប់ប តស់ស្វ យលាវ

៥ ក្បួនភៅផិតហារ

---

១ បិទ្ធតក្រុមកណាគ័រ្លួនពារ —

ក្រសួងលេខទ្រូវិតយ —

ពាក្យបទ្ធបក្សាច័តវោនយីរ ជតិណារជ័រវ៉ាន ព្រះត្រៃត្រួបក្សារ

៩ ចម្រើនក្រសួងនគរនគរ

## សៀវភៅដែលគួរអាន

ក្នុងខែនេះសៀវភៅដែលលេចជាងគេមានបួនគឺ

១-គុកគឺឋានសួរ (កំណាព្យ)

២ បញ្ហាសហករណ៍នៅប្រទេសខ្មែរ (សៀវភៅសិក្សា)

៣-អំពីរឿងជាតិ (ជ័)

២-ទូលីកំណែន (ប្រលោមលោក)

១ គុកគឺឋានសួគ៌ – ជាយោបល់របស់លោកគង់សេរី អ្នកនិពន្ធដូចបានប្រាប់យើងនៅក្នុងអារម្ភកថា ។ យើងយល់ឃើញថាទស្សនមួយគួរសរសើរ គឺមិនធ្វើឲ្យយើងអណ្តែតអណ្តូងលើអាកាសទេ គឺច្បាស់ជាចេញពីការរស់នៅដ៏ជាក់ស្តែងនៃសង្គមខ្មែរសព្វថ្ងៃ ។ ដូចនោះសៀវភៅនេះធ្វើឲ្យយើងភ្ញាក់រលឹក ដុះខាត់សតិសម្បជញ្ញៈ ជម្រុះផ្តត់គំនិតអាណានិគមចក្រពត្រនិយមចោលចេញ ។

២--បញ្ហាសហករណ៍ នៅប្រទេសខ្មែរ តែងដោយលោក

ហ៊ូ-យន់ បណ្ឌិតវិទ្យាសាស្ត្រ សេដ្ឋកិច្ច ។ ក្នុងសៀវភៅនេះ អ្នកនិពន្ធបាន ពន្យល់យើង អ្វីដែលហៅថាសហករណ៍? ចលនាសហករណ៍កើតពីណាមក? មានសហករណ៍អ្វីខ្លះ? ហេតុអ្វីបានជាស្រុកយើងត្រូវការបង្កើតសហករណ៍? សំនួរអស់នេះអ្នកនិពន្ធបានញែកវែកដ៏គ្រោះក្រាយ គេឧទាហរណ៍ដែល ងាយៗឲ្យឆាប់យល់ ។ ដូច្នេះសង្គមខ្មែរយើងសព្វថ្ងៃ មិនថាបណ្ឌិតតូចធំ ឬ អ្នកស្រែចំការទេ ត្រូវអប់រំបំពោះខ្លួនទៅគ្រប់នាទីទាំងអស់ ដើម្បីកសាង មូលដ្ឋានស្ថាបនាប្រទេសជាតិមាតុភូមិ ។

-- អំពីរឿងជាតិ (លោកគាំវេតជាអ្នកនិពន្ធ) ជាសៀវភៅសិក្សាមួយ ប្រកបដោយទស្សនៈ ដែលអាចនាំអ្នកអានឲ្យស្គាល់ អំពីបញ្ហាជាតិ ពិសេស គឺជាតិខ្មែរ ។ ក្នុងរឿងនេះអ្នកនិពន្ធបានចែកជាចំពូកដោយបានធ្វើអត្ថាធិ-ប្បាយតាមលំដាប់ អំពីលក្ខណៈរបស់ជាតិ = អំពីការវិវត្តន៍នៃជាតិក្នុងលោក សារសំខាន់នៃជាតិ ។ល។

ក្លឹតាំងលោភ ឆ ជាប្រលោមលោកបំរើនមួយក្នុងក្រលោមលោកឯទៀត ។ អ្នកនិពន្ធទាញសតិយើងឲ្យខ្ចាប់ផ្សារនឹងទុក្ខវេទនានៃប្រជាជនខ្មែរ នៅពេលជប៉ុនចូលស្រុក នៅពេលបារាំងត្រឡប់មកវិញ នៅពេលអសន្តិ-សុខ ។ រួចបានបញ្ជាក់នូវអនាគតដ៏ភ្លឺស្វាងនៃស្រុកយើងក្រោយដែលបាន សន្តិភាពមកវិញ ក្រោមការដឹកនាំនៃសម្ដេចព្រះឧបយុវរាជ ។

## លទ្ធផលនៃការសិក្សា

*តារាងខាងក្រោមនេះអាចនឹងជំរាបមិត្តអ្នកអានអំពីស្ថានភាព នៃការប្រឡងផ្សេង ៗ នៅប្រទេសយើងក្នុងរយៈពីរឆ្នាំមុន ។ (ចំពោះលទ្ធផល ឆ្នាំ ១៩៥៥-៥៦ យើងនឹងជូននៅទស្សនាវដ្ដីលេខក្រោយ ព្រោះក្នុងពេលនេះការប្រឡងលើកទីពីរកំពង់ធ្វើមិនទាន់រួច)*

(សូមមើលតារាងទំព័របន្ទាប់)

---

## ខ្វាក់តែមើលឃើញច្បាស់

តាខ្វាក់ម្នាក់បានកប់មាសមួយដុំធំនៅក្នុងសួនច្បាររបស់គាត់ ។ បានលបមើលឃើញអ្នកនៅជិតខាងម្នាក់មកលួចយកបាត់ទៅ ។ តាខ្វាក់ក៏បានដឹងច្បាស់មុខអ្នកលួច ។ តែធ្វើម្ដេចនឹងយកវិញបាន? គាត់ក៏ទៅប្រាប់អ្នកលួចនោះថា មិត្តអើយខ្ញុំមានរឿងមួយនឹងសូមឲ្យមិត្តជួយយោបល់ ខ្ញុំមានមាសពីរដុំ កប់កន្លែងខុសគ្នា មួយដុំកប់នៅកន្លែងកក្រត់ល្អ តើយើងត្រូវយកមកដាក់ជាមួយគ្នាឬ? អ្នកលួចនឹកថាខ្លួនអាចនឹងលួចបានមាសមួយដុំទៀត ក៏និយាយប្រាប់តានោះថាគួរតែយកមកដាក់ជាមួយគ្នា ។ រួចហើយចោរលួចប្រញិកប្រញាប់យកមាសដែលខ្លួនបានលួចមកកប់កន្លែងដដែលវិញ ហើយសង្ឃឹមថានឹងលួចបានទាំងពីរដុំ ។

តែផ្ទុយវិញ តាខ្វាក់បានឱកាសហើយស្រវ៉ាយកមាសរបស់គាត់យ៉ាងស្រួល ។

| សញ្ញាបត្រ | ឆ្នាំសិក្សា | ចំនួនសិស្សប្រឡង | ចំនួនសិស្សដែលប្រឡងជាប់ | ចំនួនសិស្សប្រឡងជាប់ក្នុងភាគរយ |
|---|---|---|---|---|
| មធ្យមសិក្សាប័ត្រទី២ | ១៩៥៣-៥៤ | ៨៩ | ២២ | ២៤ % |
| មធ្យមសិក្សាបត្រ ១ | —ដ— | ១៤៧ | ៤០ | ២៧ % |
| សញ្ញាបត្រ ( ឌីបូម ) | —ដ— | ៤៥៥ | ១៣១ | ២៨ % |
| វិញ្ញាបនបត្រ | —ដ— | ៦៦៥៣ | ៤០៤៤ | ៦៧ % |
| មធ្យមសិក្សាបត្រទី ២ | ១៩៥៤-៥៥ | ៦៥ | ៣៧ | ៥៧ % |
| មធ្យមសិក្សាបត្រទី ១ | —ដ— | ១៤៤ | ៦១ | ៤៣ % |
| សញ្ញាបត្រ ( ឌីបូម ) | —ដ— | ៦០៧ | ១៣២ | ២១ % |
| វិញ្ញាបនបត្រ | —ដ— | ៨៦៧២ | ៣២៤៥ | ៣៧ % |

## នាមនិស្សិតដែលទៅបន្តវិជ្ជានៅបរទេស
## ក្នុងឆ្នាំសិក្សា ១៩៥៦–១៩៥៧

| | | | | |
|---|---|---|---|---|
| ១ - | កញ្ញា ឡូ-ភាដី | វិជ្ជា | ឱសថស្ថាន | នៅប្រទេសបារាំង |
| ២ - | „ ផូស្វូជាតា | „ | សាស្ត្រាចារ្យ | –ដ– |
| ៣ - | លិម ស៊ុនឌេ | „ | ទន្តពេទ្យ | –ដ– |
| ៤ - | ហ៊ុយ-គិម្ហាវ៉ា | „ | „ | –ដ– |
| ៥ - | លិ-សេ | „ | បសុពេទ្យ | –ដ– |
| ៦ - | អ៊ុយ-ភាន់ឌុន | „ | វិស្វករ | –ដ– |
| ៧ - | តាន់-ប៊ុនសរ | „ | „ | –ដ– |
| ៨ - | តុត-ស៊ី | „ | „ | –ដ– |
| ៩ - | ជៃ-ប៊ុន ១ | „ | „ | –ដ– |
| ១០ - | ចាន់-ព្រៀងជ្រៀវ | „ | វិស្វករអាគ្រូណូមិក | នៅប្រទេសបែលស៊ិក |
| ១១ - | ហាក់-យូលិម | „ | „ | –ដ– |
| ១២ - | ហ៊ុំ-សារិត | „ | គីមីឧស្សាហកម្ម | នៅប្រទេសកាណាដា |
| ១៣ - | តាន់ហាយសៀនហៅយក់ហូ | „ | „ | –ដ– |
| ១៤ - | អ៊ុង-គិមសេង | „ | „ | –ដ– |
| ១៥ - | ដុំ-កែម | „ | វិចិត្រសិល្បៈនៅសភាបណ្ឌិតក្រុងរោម (អ៊ីតាលី) | |

# សំណួរកំសាន្ត

មិត្តអ្នកអាន!

មិត្តអាចនឹងឆ្លើយសំនួរខាងក្រោមនេះបានឬទេ?

(សូមផ្ទៀងចម្លើយរបស់មិត្តនៅទំព័របន្ទាប់)

១– ផែនដីយើងមានអាយុប៉ុន្មានឆ្នាំហើយ? ១សែនឆ្នាំ - ១លានឆ្នាំ ឬ ៣ពាន់លានឆ្នាំ?

២– អ្វីជាមេបម្លង់ដំនៃជម្ងឺអាសន្នរោគ? ទឹក-កណ្ដុរ-ចៃ ឬសង្កើច?

៣– ដល់អាយុប៉ុន្មានឆ្នាំទើបកូនដំរីឈប់បៅ? ៥ខែ - ១០ខែ - ៥ឆ្នាំ ឬ១០ឆ្នាំ?

៤– អ្នកណាបានបង្កើតក្រដាស? ជនជាតិចិន? ជនជាតិអេស៊ីប?

៥– «ទឹកធ្ងន់» (Eau lourde) ជាវត្ថុសម្រាប់ធ្វើថាមពលបរមាណូ (energie atomique) តើគេបានធ្វើ «ទឹកធ្ងន់» នេះនៅប្រទេសណា? ពីឆ្នាំណា?

# ចម្លើយសំនួរ

១–៣ពាន់លានឆ្នាំ ។ គេអាចដឹងរាប់បានតាមការពិនិត្យនៃធាតុវិទ្យុសកម្ម (radioactivités)

២– ទឹក- ការចម្លងបណ្ដាលមកពីការប៉ះពាល់ផ្ទាល់ជាមួយនឹងអ្នកជម្ងឺ ប៉ុន្តែបានជាថាទឹកជាមេចម្លងធំ ព្រោះជាវត្ថុរាវ ហើយមេរោគអាចនឹងយកធ្វើជាស្ថានបំឡងដោយងាយ ផ្លែឈើ បន្លែ មានជាប់មេរោគនេះដោយសារតែទឹកដែលគេយកទៅស្រោច ។

៣–ដល់អាយុ ៥ ឆ្នាំ ទើបកូនដំរីឈប់បៅ ។ គេយកមកប្រើប្រាស់ដល់អាយុ ១៦ ឬ១៨ ឆ្នាំ ដំរីចាស់លែងធ្វើការបានក្នុងអាយុ ៧៥ ឆ្នាំ

៤–ជនជាតិចិន បានបង្កើតក្រដាសមុនគេបង្អស់ ។ តែមិនយកមកប្រើប្រាស់ជាសំបុត្រស្នាមឡើយ ។ ហើយបាននាំយកមកប្រទេសអ៊ីស្លាម លុះដល់សតវត្សទី ៨ ទើបជនជាតិនៅមជ្ឈិមបូពា៌ (បាកដាដ ទឹងដាមា) បានធ្វើឡើងទៀត ។

នៅប្រទេសអឺរ៉ុប ជនជាតិ អេស្ប៉ាញប្រើមុនគេបង្អស់ ។

៥— គេធ្វើ «ទឹកធ្ងន់» នៅប្រទេសនរវែស (norvège) ពីឆ្នាំ ១៩៣៩ ព្រោះនៅប្រទេសនេះថាមពលអគ្គិសនីមានតម្លៃថោកណាស់ គេចំរាញ់យក «ទឹកធ្ងន់» ពីទឹកធម្មតាដោយប្រើអគ្គិសនីជាអេលេចត្រូលីស៍ (electrolyse) ។ គេបាន «ទឹកធ្ងន់» ចំនួនតិចណាស់ គឺបាន១/៥០០០ (១ភាគ៥ពាន់) ក្នុងទឹកធម្មតា កាលក្នុងមហាសង្គ្រាមលើកទីពីរ ក្នុងឆ្នាំ ១៩៣៩ សម្ពន្ធមិត្តបានទៅលបយក «ទឹកធ្ងន់» ពីប្រទេសនរវែសបានមុន ដើម្បីនឹងយកមកធ្វើគ្រាប់បែកបរមាណូ ។ ពួកអ្នកទៅយកបានពើបប្រទះនឹងទ័ពសត្រូវជាច្រើន ព្រោះពេលនោះកាលបើបានដឹងរឿងដូច្នេះ ពួកអាល្លឺម៉ង់បានដេញដណ្តើមយកទឹកនេះវិញ តែពុំបានដូចក្តីប្រាថ្នា ។ គេសន្មតហៅថាចំបាំងទឹកធ្ងន់ (bataille de l'eau lourde).

---

មឹះ ៗ មុខគេរាបរមៀទម

គោះ គៀរក្រមុំក្នុងទីស្ងាត់

ឆ្នាំ ង បាយ, កកាយលួចទៅបាត់

ឆ្នុះ ឆ្ងាយ, ប្រយ័ត្ន! មនុស្សបែបហ្នឹង ។

(ញូង-សៀង)

ស្រង់ពីទស្សនាវដ្ដីកម្ពុជសុរិយា

ព្រះអាទិត្យភ្លឺតែថ្ងៃ

ព្រះចន្ទថ្លាថ្លៃភ្លឺតែយប់

ភ្លើងភ្លឺតែក្នុងទីងងឹតស្លប់

វិជ្ជាភ្លឺសព្វគ្រប់ទិសទី ។

ឃុនពាណិជ្ជ
ផ្ទះលេខ ១៣៥ មហាវិថីព្រះស៊ីសុវត្ថិ ភ្នំពេញ

១០ រៀល